ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

*ថ្ងៃ ចន្ទ ៣ កើត ខែ កត្តិក ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤*

*រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០២០*

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពីជំនួបពិភាក្សាការងាររវាង ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាមួយលោក Yasuhisa Ojima ប្រធានស្ថានតំណាងមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ប្រចាំកម្ពុជា

នាព្រឹកថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០២០, នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានទទួលជួបពិភាក្សាការងារជាមួយលោក **Yasuhisa Ojima** ប្រធានស្ថានតំណាងមូលនិធិរូបិយវត្ថុអន្តរជាតិ (International Monetary Fund - IMF) ប្រចាំកម្ពុជា ពិភាក្សាអំពីវិធានការក្នុងការធានាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុកម្ពុជា ក៏ដូចជាការរៀបចំនូវវិធានការគោលនយោបាយសម្រាប់ស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ក្នុងវិបត្តិនៃជំងឺកូវីឌ ១៩ និងគ្រោះធម្មជាតិ ។

ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** បានសម្តែងនូវអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះមូលនិធិរូបិយវត្ថុអន្តរជាតិ ដែលជានិច្ចជាកាល រួមជាមួយដៃគូអភិវឌ្ឍន៍ផ្សេងទៀត បន្តរួមសុខទុក្ខជាមួយកម្ពុជា ជាពិសេសក្នុងកាលៈទេសៈដ៏លំបាកកំពុងបង្កឡើងដោយវិបត្តិជំងឺកូវីដ-១៩ ។ មូលនិធិរូបិយវត្ថុអន្តរជាតិ មានតួនាទីសំខាន់ក្នុងការបន្តតាមដាន និងវាយតម្លៃការវិវត្តសេដ្ឋកិច្ចសកល, តំបន់ និងកម្ពុជា, និងផ្តល់ការសិក្សាផ្សេងៗ ដែលអាចជាធាតុចូលសម្រាប់កម្ពុជា ក្នុងការបន្តរៀបចំវិធានការពាក់ព័ន្ធក្នុងការធានាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុកម្ពុជា និងការរៀបចំនូវវិធានការគោលនយោបាយសម្រាប់ស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ។

ទោះបីជាកម្ពុជាត្រូវបានវាយតម្លៃ និងទទួលស្គាល់ថាជាប្រទេសមួយក្នុងចំណោមប្រទេសដែលគ្រប់គ្រងស្ថានភាពជំងឺកូវីដ-១៩ បានល្អប្រសើរ, រាជរដ្ឋាភិបាលកម្ពុជា នៅបន្តតាមដានការវិវត្តនៃជំងឺនេះដោយយកចិត្តទុកដាក់ខ្ពស់ និងពុំមើលស្រាលស្ថានការ ដោយបន្តអនុវត្តនូវវិធានការសុខាភិបាល រួមជាមួយការចាត់វិធានការមុតស្រួចក្នុងការគាំទ្រលំនឹងសេដ្ឋកិច្ច និងជីវភាពប្រជាជន ។ ឈរលើមូលដ្ឋាននេះ, សកម្មភាពសេដ្ឋកិច្ចកម្ពុជាអាចបន្តមានប្រក្រតីភាពល្អ ខណៈស្ថានភាពសារពើពន្ធ ជាពិសេស ផ្នែកចំណូលពន្ធនឹងមានភាពប្រសើរជាងការរំពឹងទុក ដែលនេះជាបច្ច័យល្អ

សម្រាប់ការអនុវត្តថវិកាឆ្នាំ ២០២១ ដោយអនុញ្ញាតឱ្យមានលំហថវិកាធំ និងការប្រើប្រាស់ប្រាក់សន្សំរបស់រាជរដ្ឋាភិបាលតិចជាងការរំពឹងទុក ។ ប៉ុន្តែថ្មីៗនេះ, ផលប៉ះពាល់ពីជំនន់ទឹកភ្លៀង បាន និងកំពុងដាក់សម្ពាធមួយផ្នែកវិញដល់បន្ទុកចំណាយរដ្ឋ ពិសេស ការស្តារឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន និងធារាសាស្រ្ត ។

ទោះជាយ៉ាង, រាជរដ្ឋាភិបាលកម្ពុជា បាន និងកំពុងរៀបចំផែនការស្តារសេដ្ឋកិច្ចក្រោយវិបត្តិជំងឺកូវីដ-១៩ (Post Covid-19 Recovery Plan) ដែលជាការគិតគូរសម្រាប់រយៈពេលមធ្យមក្នុងការជំរុញកំណើនសេដ្ឋកិច្ចឱ្យត្រឡប់ទៅរកសក្តានុពលវិញឱ្យបានលឿន ។

លោក **Yasuhisa Ojima** បានវាយតម្លៃខ្ពស់ចំពោះភាពជោគជ័យរបស់កម្ពុជាក្នុងការប្រយុទ្ធប្រឆាំង និងគ្រប់គ្រងបានល្អប្រសើរនូវការរីករាលដាននៃជំងឺកូវីដ-១៩ នៅកម្ពុជា ពិសេស ប្រសិទ្ធភាពនៃការអនុវត្តនូវវិធានការមុតស្រួច ថ្មីៗ នានាក្រោមក្របខណ្ឌយុទ្ធសាស្រ្តស្តារសេដ្ឋកិច្ចឡើងវិញក្រោយវិបត្តិជំងឺកូវីដ ១៩ និងកម្មវិធីគាំពារសង្គម ជាដើម ។ ជាមួយគ្នានេះ, លោកប្រធានស្ថានតំណាងបានគាំទ្រស្មារតីប្រុងប្រយ័ត្នខ្ពស់របស់រាជរដ្ឋាភិបាលតាមរយៈការបន្តតាមដានការប្រែប្រួលស្ថានការម៉ាក្រូសេដ្ឋកិច្ច និងបានលើកទឹកចិត្តឱ្យបន្តកិច្ចសហការជាមួយធនាគារជាតិនៃកម្ពុជា ក្នុងការឃ្លាំមើលការប្រែប្រួលនៃស្ថានភាពសេដ្ឋកិច្ច ទាំងកម្រិតសកល និងតំបន់ ។ លោក **Yasuhisa Ojima** បានអះអាងថា មូលនិធិរូបិយវត្ថុអន្តរជាតិ នឹងបន្តជួយគាំទ្រកម្ពុជាតាមរយៈការបន្តកិច្ចសហប្រតិបត្តិការជាប្រពៃណីកន្លងមក និងបានគូសបញ្ជាក់ពីក្របខណ្ឌនៃកិច្ចសហប្រតិបត្តិការពិសេស ក្នុងនោះរួមមានមូលនិធិហិរញ្ញប្បទានរហ័ស (Rapid Financing Facility) ដែលអាចជាជម្រើសមួយបន្ថែមសម្រាប់កម្ពុជាក្នុងការបំពេញកង្វះខាតហិរញ្ញប្បទានសម្រាប់ផែនការស្តារសេដ្ឋកិច្ចក្រោយវិបត្តិជំងឺកូវីដ-១៩ ។

ជាទីបញ្ចប់, ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី ក៏បានថ្លែងអំណរគុណជាថ្មីម្តងទៀតដល់ការគាំទ្រ និងកិច្ចសហប្រតិបត្តិការល្អប្រសើររបស់មូលនិធិរូបិយវត្ថុអន្តរជាតិ ដែលបានគាំទ្រដល់ការពង្រឹងសមត្ថភាព, ការបណ្តុះបណ្តាលមន្ត្រីរាជការ ក៏ដូចជាជំនួយបច្ចេកទេសដល់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងស្ថាប័នពាក់ព័ន្ធនានា ដែលកន្លងមកបានរួមចំណែកយ៉ាងសំខាន់ក្នុងការពង្រឹងសមត្ថភាពស្ថាប័នរាជរដ្ឋាភិបាលកម្ពុជា ។